# ទំនុកដំកើង ១៣១

អ្នកនិពន្ធ រុហ្វ លេភិឡារ

មាតិកានៅក្នុងទំនុកដំកើងជាមួយនឹងឈ្មោះរបស់ដាវីឌនៅដើមដំបូងទំនុកដំកើងនេះ រំលឹកយើងអំពីការបន្ទាបខ្លួនរបស់គាត់នៅក្នុងជីវិតដំបូងរបស់គាត់ដែលជាគុណភាពមួយដែលបានជួយឲ្យគាត់បានខ្លាំងពូកែ។ បន្ទាប់ពីការចាប់ផ្ដើមល្អរបស់គាត់ ជួនកាលដាវីឌមិនបានបង្ហាញគុណភាពនានាដែលត្រូវបានពិពណ៌នានៅក្នុងទំនុកដំកើងនេះទេ។ អ្នកខ្លះបានបដិសេធការច្រៀងទំនុកដំកើងរបស់ ដាវីឌដោយព្រោះមានមនុស្សជាច្រើនមានអំនួត ហើយដូច្នេះ មិនអាចនិយាយថា « ចិត្តរបស់ទូលបង្គំមិនមែនឆ្មើងឆ្មៃ»...ល. ពីព្រោះបើសិនជាពួកគេច្រៀង នោះគេច្រៀងកុហក។ វាជាការពិតដែលយើងមានអំនួត ហើយគួរតែគិតអំពីពាក្យមុននឹងយើងច្រៀង ប៉ុន្តែយើងអាចច្រៀងវាសំរាប់គោលបំណងដូចដែលយើងអានវាផងដែរ ដើម្បីបង្រៀននិងដាស់តឿនខ្លួនឯង និងចំពោះគ្នាទៅវិញទៅមក យើងគួរតែប្រែចិត្តហើយអធិស្ឋានដោយបន្ទាបខ្លួនទៅចំពោះព្រះសំរាប់ព្រះគុណរបស់ទ្រង់ដើម្បីទ្រង់ប្រទានចិត្តដែលត្រូវបានពិពណ៌នានៅក្នុងទំនុកដំកើងនេះ។

**ខ. ១** *ភ្នែកទូលបង្គំក៏មិនប្រកាន់យស* ប្រសិនបើមនុស្សម្នាក់មានចិត្តអួត គាត់ជារឿយៗមានការសំឡឹងមើលដោយអំនួតដែរ (សុភាសិត ៦:១៧) ក៏មើលដោយសេចក្ដីច្រណែនទៅអស់អ្នកដែលខ្ពស់ជាងគាត់ ឬមើលដោយសេចក្ដីមើលងាយទៅលើអស់អ្នកដែលទាបជាងគាត់។ ខនេះបង្ហាញថា យើងគួរតែដឹងអំពីដែនកំណត់ដែលព្រះ បានប្រទានមកឲ្យយើង ហើយមិនត្រូវធ្វើសកម្មភាពឥតប្រយោជន៍ដោយព្យាយាមសំរេចឲ្យបានលើសដែនកំណត់នោះឡើយ។ ឥរិយាបថនេះមានភាពវៃឆ្លាត។ មនុស្សឆ្លាតមិនព្យាយាមយល់ការដែលហួសពីអ្វីដែលគាត់អាចនោះឡើយ (ប្រៀបធៀប ចោទិយកថា ២៩:២៨ ព្រះគម្ពីរភាសាអង់គ្លេស ២៩:២៩)។

**ខ. ២** ខនេះសង្កត់ធ្ងន់លើពាក្យ «ដែលបានផ្ដាច់ដោះ»។ ក្មេងទើបតែនឹងកើតម្នាក់ត្រូវការទឹកដោះរបស់ម្ដាយរបស់គាត់ ប៉ុន្តែនៅពេលគាត់ត្រូវបានផ្ដាច់ដោះ គាត់មិនត្រូវការទៀតទេ ហើយលែងកើតទុក្ខដោយសារតែអ្វីដែលធ្លាប់តែខានមិនបានទៀតហើយ។ នេះគឺជាការពន្យល់បង្ហាញមួយថា នៅពេលយើងត្រឡប់ជាឆ្លាត យើងរៀនបានមេរៀនដូចគ្នាហើយនិងឥរិយាបថដូចគ្នា។ មនុស្សឆ្លាតបានឈប់ទាមទាររបស់ដែលគាត់លែងត្រូវការទៀត ហើយឥឡូវនេះគាត់ស្កប់ចិត្តហើយ។ ការនេះមានតាំងពីចុងបញ្ចប់ខ.១ ហើយបានពិពណ៌នាភាពផ្ទុយគ្នាពី *យកចិត្តទុកដាក់ក្នុងការដ៏ធំ ឬក្នុងដំណើរដែលអស្ចារ្យហួសល្បត់ទូលបង្គំឡើយ*។

**ខ. ៣** ទំនុកដំកើងនេះបញ្ចប់ដោយការហៅទៅកាន់អ៊ីស្រាអែលដូចគ្នានឹងការហៅនៅក្នុងទំនុកដំកើង ១៣០ (ខ. ៧)។ យើងគួរតែឈប់ដេញតាមមហិច្ឆតាឥតប្រយោជន៍ តែផ្ទុយទៅវិញគួរតែធ្វើឲ្យព្រលឹងរបស់យើងស្ងប់ស្ងាត់ (ខ. ២) ដោយការដាក់សេចក្ដីសង្ឃឹមរបស់យើងនៅក្នុងព្រះយ៉ាវេ។

**ការអនុវត្ត**

ទំនុកដំកើងនេះបង្រៀនអំពីប្រាជ្ញាដ៏អស្ចារ្យ គឺថាឥរិយាបថត្រឹមត្រូវរបស់យើងត្រូវតែមានសង្ឃឹមដោយបន្ទាបខ្លួននៅក្នុងព្រះ ហើយមិនត្រូវព្យាយាមយល់លើសពីអ្វីដែលព្រះបានប្រទានមកឲ្យយើងមាននោះឡើយ។ ការនេះមិនមែនលើកទឹកចិត្តឲ្យយើងប្រើគំនិតរបស់យើងដោយភាពខ្ជិលច្រអូសនោះទេ តែទទូចឲ្យយើងមានការប្រមាណខ្លួនឯងមួយដែលត្រឹមត្រូវនិងបន្ទាបខ្លួនដែលនាំយើងឲ្យមានសង្ឃឹមក្នុងព្រះវិញ។ ដូច្នេះ មេរៀននេះស្រដៀងនឹងសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវ

អំពីការចូលនិងក្លាយជាអ្នកធំនៅក្នុងនគរព្រះដែរ (ម៉ាថាយ ១៨:១-៤)។ នៅក្នុងកណ្ឌភីលីព សាវ័កប៉ុលបង្រៀនមេរៀនដែលមានផ្ទៃរឿងដូចគ្នានឹងទំនុកដំកើងនេះ ពីព្រោះគាត់បង្រៀនថា ឥរិយាបថរបស់យើងគួរតែដូចជាព្រះយេស៊ូវដែលទ្រង់បានបន្ទាបអង្គទ្រង់ (២:៣-១១)។ កាសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងមិនគ្រាន់តែបើកសំដែងអំពីការបន្ទាបអង្គទ្រង់នោះទេ ប៉ុន្តែក៏បើកសំដែងអំពីការស្តាប់បង្គាប់ដែលបានមកពីសេចក្តីសង្ឃឹមដែលទ្រង់មានផងដែរ (ហេព្រើរ ១២:១-២)។

### Bibliography


Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries (465–467). Nottingham, England: Inter-Varsity Press.

Matthews, V. H., M. W. Chavalas & J.H. Walton (2000), *The IVP Bible background commentary: Old Testament*, Downers Grove, IL: InterVarsity Press.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.